ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ
លេខ.........................................

# របាយការណ៍

## បូកសរុបលទ្ធផលការងារប្រចាំខែមីនា ឆ្នាំ២០២២

**ក-អំពីកម្លាំង៖**

សរុបរួមចំនួន៖ ០៥នាក់ (ស្រី០២នាក់) អវត្តមាន៖ ០០

**ខ-សកម្មភាព និងលទ្ធផលការងារ**

ខ.១-កិច្ចប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាងគោលនយោបាយ និងបទដ្ឋានគតិយុត្តិនានា

<u>សកម្មភាពក្នុងស្រុក</u>

- **ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង លោកឧត្តមសេនីយ៍ត្រី អ៊ុន មាន ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យខ្លឹមសាររបាយការណ៍ ឆ្នាំ២០២១ របស់គណៈកម្មាធិការធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ ឧត្តមសេនីយ៍ឯក ប៊ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ ដែលមានការអញ្ជើញចូលរួមពីពី ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធាន អនុប្រធានក្រុមជំនួយកិច្ចការទាំង៦ និងក្រុមការងារបច្ចេកទេសរបាយការណ៍ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។

- **ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងវិស័យនេសាទ នៅអាស៊ីអាគ្នេយ៍ រៀបចំសម្របសម្រួលដោយបណ្តាញភ្នាក់ងារគាំពារលើវិស័យការងារ Labour protection network (LPN) របស់គម្រោងអាស៊ាន-អូស្ត្រាលី ASIAN-Australia លើវិស័យប្រឆាំងការជួញដូរមនុស្ស ។ សមាសភាពអញ្ជើញចូលរួមមាន លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គជបជ ភាគីពាក់ព័ន្ធ អាស៊ានអូស្ត្រាលី អ្នកអនុវត្តការងារ លើវិស័យនេសាទ តំណាងពីសមាជិកប្រទេស នៃសហគមន៍អាស៊ាន ដែលមានមានអ្នកចូលរួមប្រមាណ ៥០០នាក់ ។

- **ថ្ងៃទី១០-១១ ខែមីនា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការចម្រុះលើកទី១១ រវាងកម្ពុជា និងសហភាពអឺរ៉ុប (EU) ដែលបានរៀបចំឡើងនៅរាជធានីភ្នំពេញ ក្នុងទម្រង់ដោយផ្ទាល់ផង និងតាមរយៈវីដេអូពីចម្ងាយផង ដែលមានរយៈ

ពេល២ថ្ងៃ។ កិច្ចប្រជុំគណៈកម្មាធិការចម្រុះនេះ ដឹកនាំដោយ ឯកឧត្តម លុយ ដាវីត រដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងលោកស្រី Paola PAMPALONI អនុប្រធានគ្រប់គ្រងប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក នៃមន្ទីរកិច្ចការបរទេសសហភាពអឺរ៉ុប។ កិច្ចប្រជុំអនុក្រុមចំនួន ០៣ រួមមាន ពាណិជ្ជកម្ម និងការវិនិយោគ កិច្ចសហប្រតិបត្តិការ និងការកសាងស្ថាប័ន កំណែទម្រង់រដ្ឋបាល កំណែទម្រង់ច្បាប់ និងយុត្តិធម៌ អភិបាលកិច្ច និងសិទ្ធិមនុស្ស។ កិច្ចប្រជុំបានពិនិត្យលើវឌ្ឍនភាពសម្រេចបាន គិតចាប់តាំងពីកិច្ចប្រជុំគណៈកម្មាធិការចម្រុះ កម្ពុជា-សហភាពអឺរ៉ុបលើកទី១០ ដែលបានប្រព្រឹត្តទៅនៅទីក្រុងប្រ៊ុចសែល ក្នុងឆ្នាំ២០១៨ ព្រមទាំងបានផ្លាស់ប្តូរទស្សនលើប្រធានបទជាច្រើនពាក់ព័ន្ធនឹងបញ្ហាទ្វេភាគី និងពហុភាគី ក្នុងនោះរួមទាំងការវិវត្តនយោបាយថ្មីៗទាំងនៅកម្ពុជា និងសហភាពអឺរ៉ុបផងដែរ។

- **ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បានអញ្ជើញចូលរួមកិច្ចប្រជុំបន្តដើម្បីពិនិត្យ និងកែសម្រួល ខ្លឹមសារ និងប្រមូលធាតុចូលលើឯកសា SOP សម្រាប់កិច្ចប្រជុំទ្វេភាគី វាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអភិវឌ្ឍន៍ សង្គម និងសន្តិសុខមនុស្សនៃ រាជរដ្ឋាភិបាលថៃស្តីពី «ស្តង់ដារនៃនីតិវិធីប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់» ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គជបជ ។ សមាសភាពអញ្ជើញចូលរួមមាន ឯកឧត្តម ហ៊ូ វឌ្ឍី រដ្ឋលេខាធិការ ក្រសួងការងារបណ្តុះបណ្តាល វិជ្ជាជីវៈ លោក អ៊ុក រ៉ាវុធ អនុប្រធាននាយកដ្ឋានមុខរបប នៃក្រសួងការងារ ឯកឧត្តម មុំ ប៊ុនថន រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា លោកស្រី ព្រុំ សុខន ប្រធាននាយកដ្ឋាន ឯកឧត្តម សុន ពិសិដ្ឋ អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ លោកស្រី សុន សុខាលីដា ប្រធាននាយកដ្ឋាន ព្រហ្មទណ្ឌនិងច្បាប់ លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរង នគរបាលជាតិ ឧត្តមសេនីយ៍ ប៉ាក់យូលៀង អនុប្រធាននាយកដ្ឋាន លោកវរសេនីយ៍ឯក លៅ លីន អនុនាយកដ្ឋាន ឯកឧត្តម កែវ វិសិដ្ឋ អនុរដ្ឋលេខាធិការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ លោក ជ័យ រដ្ឋា ប្រធាននាយកដ្ឋាន លោកហន ឧសភា អនុប្រធានការិយាល័យ លោក ឯក សំអុល តំណាងអង្គការ IOM លោក សេកសារឿន តំណាអង្គការIJM អគ្គលេខាធិការដ្ឋាន (គ.ជ.ប.ជ) លោកជំទាវឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ និង ឯកឧត្តម លោកជំទាវអគ្គលេខាធិការរង ប្រធានក្រុមការងារ ០៦ ប្រធានលេខាធិការដ្ឋាន និង ក្រុមការងារបច្ចេកទេស។

- **ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង លោកស្រីវរសេនីយ៍ទោ ថោង សុវត្ថី អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សាយុទ្ធសាស្ត្រ ស្តីពីកិច្ចការពារសិទ្ធិ និងសុវត្ថិភាពពលករទេសន្តរប្រវេសន៍ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយអង្គការវីនរ៉ក់អន្តរជាតិ ដែលមាន **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ និងឯកឧត្តម ហ៊ូ វុទ្ធី រដ្ឋលេខាធិការក្រសួងការងារ តំណាងឱ្យ គ.ជ.ប.ជ បានអញ្ជើញជាអធិបតីភាព។ សមាសភាពចូលរួមមាន លោក ម៉ាក ថៃយល័រ ប្រធានគម្រោងប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ លោកឧត្តមសេនីយ៍ឯក លី តុងហ៊ុយ អគ្គលេខាធិការរង ក្រុមជំនួយកិច្ចការការពារ

ជនរងគ្រោះ លោកឧត្តមសេនីយ៍ទោ រ៉ន សុភ័ក្រវឌ្ឍនា ប្រធានក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់ លោកប្រធាន និងអនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ ពីក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានអ្នកអនុវត្ត គម្រោងរបស់អង្គការវីនរ៉ក់ និងសហការី និងអ្នកពាក់ព័ន្ធការងារជាមួយនិងងពលករទេសន្តរប្រវេសន៍ ។ កិច្ចប្រជុំពិភាក្សានេះមានគោលបំណង បង្កើតនៅយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការងារដែលផ្តោតលើកិច្ចការពារសិទ្ធិ សុវត្ថិភាព ពលករទេសន្តរប្រវេសន៍ និងកិច្ចខិតខំប្រឹងប្រែង របស់កម្ពុជាប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសបរិបទនៃកិច្ចសហប្រតិបត្តិការទ្វេរ ភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ដើម្បីលុបបំបាត់ ការជួញដូរមនុស្ស និងជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

- **ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សា "កិច្ចប្រជុំបច្ចេកទេសដើម្បីពិនិត្យខ្លឹមសារ ស្តង់ដារនៃនីតិវិធីប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការក្នុងការអនុវត្តច្បាប់(SOP) រវាងកម្ពុជា និងថៃ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងមានការអញ្ជើញចូលរួមពីលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានក្រុមជំនួយកិច្ចការ ទីប្រឹក្សា ប្រធានលេខាធិការដ្ឋាន ក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ, និងមានការអញ្ជើញចូលរួមពីមន្ត្រីជំនាញដែលមកពីអន្តរក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូជាតិ និងអន្តរជាតិ ដែលមានវត្តមាននៅក្នុងអង្គប្រជុំនោះចំនួន៣១រូប (ស្រី១១រូប)

- **ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២** លោកឧត្តមសេនីយ៍ត្រី អ៊ុន មាន ប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញចូលរួមក្នុង កិច្ចប្រជុំក្រុមការងារ សហប្រតិបត្តិការអន្តរជាតិ និងចែករំលែកព័ត៌មានបច្ចុប្បន្នភាព ពាក់ព័ន្ធនឹងការងាររបស់ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព **លោកជំទាវ ហ៊ូ សាមិត្ត** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី និងជាប្រធាន ក្រុមការងារខេមមីតកម្ពុជា ដែលបានប្រព្រឹត្តិទៅនៅសណ្ឋាគារហ៊ីម៉ាវ៉ារី។ កិច្ចប្រជុំនេះរៀបចំឡើងក្នុងគោលបំណងដើម្បីចែករំលែកព័ត៌មានបច្ចុប្បន្នភាព រូបភាពថ្មីនៃអំពើជួញដូរមនុស្ស គំនិតផ្តួចផ្តើមឆ្លើយតប បទពិសោធន៍ល្អៗ និងកំណត់បញ្ហាប្រឈម ស្វែងយល់អំពីតំណភ្ជាប់នៃ CEDAW ទៅនឹងគោលនយោបាយ និងផែនការជាតិ ដែលឆ្លើយតបនឹងពលករចំណាកស្រុកជាស្ត្រី ដែលបានជួបនូវ បទពិសោធន៍នៃអំពើហិង្សា និង ការជួញដូរនៅក្នុង ការធ្វើចំណាកស្រុក និងប្រមូលធាតុចូល ដើម្បីរៀបចំផែនការ របស់ក្រុមការងារឆ្នាំ ២០២២ - ២០២៣។

- **ថ្ងៃទី២៤-២៥ ខែមីនា ឆ្នាំ២០២២** លោកស្រី វរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ បានអញ្ជើញចូលរួមសម្របសម្រួល និងធ្វើជាគ្រូឧទ្ទេសនៅក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី៖ ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងផ្តល់សេវាសមស្របជាមួយរដ្ឋបាលខេត្តកោះកុង ដោយមានកិច្ចសហការ ជាមួយអង្គការ អាស៊ានអាក់ (Asian Act) ។ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជាអធិបតីភាពក្នុងពិធីបើកវគ្គ និងលោកជំទាវ មិថុនា ភូថង អភិបាលនៃគណៈអភិបាលខេត្តកោះកុង ជាគណៈអធិបតីផងដែរ។ វគ្គបណ្តុះបណ្តាលនេះធ្វើឡើងក្នុងគោលបំណង ដើម្បីឱ្យអ្នកមានភារកិច្ច កំណត់អត្តសញ្ញាណ

ជនរងគ្រោះយល់បានច្បាស់ពីនីតិវិធី និងអាចប្រើប្រាស់បែបបទដែលពាក់ព័ន្ធ ក្នុងដំណើរការនៃការកំណត់អត្តសញ្ញាណជនរងគ្រោះយល់ដឹងអំពីច្បាប់ និងអាចសន្និដ្ឋានជាបឋម ដោយភាពប្រាកដប្រជា ដើម្បីទទួលបានលទ្ធផល និងព័ត៌មានត្រឡប់ស្តីពីការប្រើប្រាស់បទដ្ឋាននានា ភាពប្រឈម និងចំណុចខ្វះខាតនៃការណែនាំក្នុងការអនុវត្តដើម្បីកែលម្អ បង្កើនប្រសិទ្ធភាពការងារ ក្នុងការផ្តល់ សេវាបឋមជូនដល់ជនរងគ្រោះ ។

- **ថ្ងៃទី២៤-២៥ ខែមីនា ឆ្នាំ២០២២** នាសាលប្រជុំសាលាខេត្តកោះកុង លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការ សហប្រតិបត្តិការអន្តរជាតិ បានសហការរៀបចំ វគ្គបណ្តុះបណ្តាលស្តីពី៖ “កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន - Training on Child Protection and Identification of Human Trafficking and Abuse” ដែលកម្មវិធីបើក វគ្គបណ្តុះបណ្តាលបាន ប្រព្រឹត្តិទៅក្រោមអធិបតីភាព លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងកម្មវិធីបិទវគ្គ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គជបជ។ វគ្គបណ្តុះបណ្តាលនេះកើតឡើងក្រោមកិច្ចសហការរវាង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយ ក្រសួងសុខាភិបាល ដោយមានជំនួយឧបត្ថម្ភពីសហភាពអឺរ៉ុប (EU) តាមរយៈ អង្គការយូនីសេហ្វ ក្នុងគោលបំណង ផ្សព្វផ្សាយឱ្យបានកាន់តែ ទូលំទូលាយ និង ពង្រឹងសមត្ថភាព ជាពិសេសការអនុវត្ត ក្រមសីលធម៌របស់មន្រ្តីនៅទីកន្លែងធ្វើចត្តាឡីស័ក ដែលបានអនុវត្តផ្ទាល់ នៅមូលដ្ឋាន សរុបចំនួន ៣៣រូប (ស្រី១០រូប) អញ្ជើញមកពី ស្រុកគីរីសាគរ និងបូទុមសាគរ នៃខេត្តកោះកុង ក្នុងចំណោមអ្នកចូលរួមសរុប ៤១រូប (ស្រី២០រូប) ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ ការបញ្ជូនករណីកុមាររងគ្រោះ និងងាយរងគ្រោះទៅកាន់ សេវាសមស្រប ដើម្បីជានា ការការពារ និង សុខមាលភាពរបស់កុមារដែលទទួលរងផលប៉ះពាល់ ពីចំណាកស្រុក។ អញ្ជើញចូលរួមជា គណៈអធិបតីមាន លោកស្រី សុខ សុជាវី ប្រធានមន្ទីកិច្ចការនារី និង ជាអនុប្រធានលេខាធិការដ្ឋាន គខបជ តំណាងឯកឧត្តមអភិបាលរង នៃគណៈអភិបាលខេត្ត និង ជាប្រធានលេខាធិការដ្ឋាន គខបជ , លោក គង់ រឿង ប្រធានមន្ទីសង្គមកិច្ច , លោកស្រី ប៉ែន អ៊ុងវីរ៉ា អនុប្រធានការិយាល័យ បង្ការ និង គ្រប់គ្រងជំងឺមន្ទីសុខាភិបាល។ ចូលរួមជាគ្រូឧទ្ទេសរួមមាន លោកជំទាវ ឧត្តមសេនីយទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការសហប្រតិបត្តិជាតិ និងអន្តរជាតិ, លោកឧត្តមសេនីយទោ កែវ ផល្លា ប្រធានក្រុម ជំនួយកិច្ចការយុត្តិធម៌, លោកវរសេនីយ៍ឯក តាវ វេភក្តិ និង លោកស្រីវរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ លោកស្រីវេជ្ជបណ្ឌិត តេង ស្រី អនុប្រធាននាយកដ្ឋាន ប្រយុទ្ធជំងឺឆ្លងនៃក្រសួងសុខាភិបាល, លោកស្រី ព្រំ សុខន ប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និង សមាហរណកម្មជនរងគ្រោះ និង លោកគ្រូ ស៊ាង លាភ អ្នកប្រឹក្សាចិត្តសាស្ត្រ នៃអង្គការជីកីអូ។

- **ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ និងអន្តរជាតិ និងជាសមាជិក នៃក្រុមការងារ SOMTC និង ជាមន្រ្តីបង្គោលផែនការងារប្រឆាំង ការជួញដូរមនុស្ស បានអញ្ជើញចូលរួមជំនួបពិភាក្សាការងារ រវាង SOMTC កម្ពុជាជាមួយប្រតិភូ ASEAN-ACT ដែលរៀបចំឡើង តាមរយៈប្រព័ន្ធវីដេអូសន្និសីទ នៅសាលប្រជុំ A1 អាគារ H ទីស្តីការក្រសួងមហាផ្ទៃ។ ក្រុមការងារ SOMTC កម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម នាយឧត្តមសេនីយ៍ ប៉ោ ភក្តិ**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ និង ជាប្រធានក្រុមការងារ ឧក្រិដ្ឋកម្មឆ្លងដែនកម្ពុជា (SOMTC) បានអញ្ជើញជួបពិភាក្សា ការងារជាមួយនឹងក្រុមការងារមកពី ក្រសួងការបរទេស និងពាណិជ្ជកម្ម នៃប្រទេស អូស្ត្រាលី (DFAT) ដែលដឹកនាំដោយលោកស្រី Danielle Sever និង ក្រុមការងារអាស៊ាន-អូស្ត្រាលី ប្រឆាំងនឹងការជួញដូរមនុស្ស (ASEAN-ACT) ដឹកនាំដោយ លោកវេជ្ជបណ្ឌិត Luda Petropaoli ។ បន្ទាប់ពី ការថ្លែងនូវមតិបើក របស់ភាគីទាំងពីរួចមក ក្រុមការងារ-SOMTC កម្ពុជា បានធ្វើបទបង្ហាញជម្រាបជូនដល់ ភាគីអូស្ត្រាលី អំពីវឌ្ឍនភាពនៃ ការទប់ស្កាត់អំពើជួញដូរមនុស្ស និង បញ្ហាប្រឈមនានា នៅក្នុងបរិបទនៃជំងឺ កូវីដ១៩។ ជាមួយគ្នានេះដែរ ក្រុមការងារ SOMTC-កម្ពុជា ក៏បានលើកឡើងនៅ សំណូមពរមួយចំនួនជាទិស ដៅបន្ត ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស ឱ្យកាន់តែមាន ប្រសិទ្ធភាពខ្ពស់បន្ថែមទៀត ជាពិសេសពាក់ព័ន្ធទៅ លើ ការបណ្តុះបណ្តាល សមត្ថភាព ដល់មន្ត្រី និង ការងារផ្សព្វផ្សាយនូវខ្លឹមសារ អនុសញ្ញា និង ឯកសារច្បាប់ នានា ពាក់ព័ន្ធនឹងការងារ ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ ឆ្លើយតបចំពោះបទបង្ហាញរបស់ ភាគីកម្ពុជា ភាគី អូស្ត្រាលីក៏បានសម្តែងនូវការប្តេជ្ញាចិត្ត ក្នុងការជួយគាំទ្រទៅដល់ សំណូមពរដែលបានលើកឡើង ហើយភាគី ទាំងពីរនឹងបន្តជជែកគ្នាបន្ថែមទៀត ដើម្បីឈានទៅរៀបចំ ដាក់ចេញការអនុវត្តជាក់ស្តែង។

- **ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២** លោកស្រី វរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការសហ ប្រតិបត្តិការជាតិ និងអន្តរជាតិ និងលោក អនុសេនីយ៍ឯក ហុក ដារី បានអញ្ជើញចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផល ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២១ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ ខ្ពង់ខ្ពស់ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប ជ លោក ជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ និងលោកជំទាវ យូ សុភា អភិបាលរងខេត្ត សៀមរាប និងមានការអញ្ជើញចូលរួមពី លោក លោកស្រី សមាជិក សមាជិកា លេខាធិការដ្ឋាន គ.ខ.ប.ជ ពី មន្ទីរអង្គភាពពាក់ព័ន្ធ រដ្ឋបាលក្រុង ស្រុក អាជ្ញាធរមានសមត្ថកិច្ច និងតំណាងអង្គការ ដៃគូជាតិអន្តរជាតិ ពាក់ ព័ន្ធ របស់រដ្ឋបាលខេត្តសៀមរាប ។ កិច្ចប្រជុំនេះផងដែរ ក៏បានលើកយកបញ្ហាជាច្រើនមកពិភាក្សា ដើម្បីស្វែង រកដំណោះស្រាយរួមគ្នាសម្រាប់ការពារជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ឬ ការរំលោភបំពានផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម ផ្លូវភេទ។

**ខ.២-ការងារចងក្រងព័ត៌មានតាមគេហទំព័រសារព័ត៌មាននានា (មានភ្ជាប់ក្នុងឧបសម្ព័ន្ធ)**

- គ្រោះថ្នាក់ ឬហានិភ័យការងារក្នុងប្រទេសគោលដៅ
    - ឧបទ្ទវហេតុ ០០ នាក់
    - ពលករសរុប ០០ នាក់
- ប្រព្រឹត្តបទល្មើសនៅនឹងកន្លែង
    - ចាប់ខ្លួន ០០ នាក់
    - ពលករសរុប ០០ នាក់
- ពលកររួចទោសពីពន្ធនាគារ
    - ពលករសរុប ០០ នាក់

- ពលករចំណាកស្រុកខុសច្បាប់
  - បញ្ជូនត្រឡប់ **៣៣៨២ នាក់**
  - ចាប់ខ្លួន **៥ នាក់**
  - ពលករសរុប **៣៣៨៧ នាក់**

**គ-ទិសដៅបន្ត**

- បណ្តុះបណ្តាលជំនាញក្រុមការងារព័ត៌មានវិទ្យាថ្មី

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២២

**ប្រធាន**

**ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ**

**ចម្លងជូនៈ**

-លេខាធិការដ្ឋានរដ្ឋបាលសរុប

-លោកជំទាវអគ្គលេខាធិការរងទទួលបន្ទុក

-លោកជំទាវអគ្គលេខាធិការ

"ដើម្បីជូនជ្រាប" ជាសេចក្តីរាយការណ៍

-ឯកសារ-កាលបវេតិ